**ព្រះរាជាណាចក្រកម្ពុជា**
**ជាតិ សាសនា ព្រះមហាក្សត្រ**

ក្រសួងសេដ្ឋកិច្ច និង ហិរញ្ញវត្ថុ

ថ្ងៃអង្គារ ១ រោច ខែមាឃ ឆ្នាំម្សាញ់ សប្តស័ក ព.ស. ២៥៦៩
រាជធានីភ្នំពេញ ថ្ងៃទី៣ ខែកុម្ភៈ គ.ស. ២០២៦

# សេចក្តីប្រកាសព័ត៌មាន
# ស្តីពី
# កិច្ចប្រជុំគណៈកម្មាធិការដឹកនាំការងារកែទម្រង់ការគ្រប់គ្រងហិរញ្ញវត្ថុសាធារណៈ ដើម្បីពិនិត្យ និងពិភាក្សាលើរបាយការណ៍តាមដាន និងវាយតម្លៃ ប្រចាំឆ្នាំ២០២៥ នៃការអនុវត្តកម្មវិធីកែទម្រង់ការគ្រប់គ្រង ហិរញ្ញវត្ថុសាធារណៈ ដំណាក់កាលទី ៤ "គណនេយ្យភាពសមិទ្ធកម្ម"

ថ្ងៃអង្គារ ១ រោច ខែមាឃ ឆ្នាំម្សាញ់ សប្តស័ក ព.ស. ២៥៦៩ ត្រូវនឹងថ្ងៃទី៣ ខែកុម្ភៈ គ.ស. ២០២៦, **ឯកឧត្តមអគ្គបណ្ឌិតសភាចារ្យ អូន ព័ន្ធមុនីរ័ត្ន ឧបនាយករដ្ឋមន្ត្រី រដ្ឋមន្ត្រីក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ** (**កសហវ.**) និងជាប្រធានគណៈកម្មាធិការដឹកនាំការងារកែទម្រង់ការគ្រប់គ្រងហិរញ្ញវត្ថុសាធារណៈ (**គ.ហ.ស.**) បានដឹកនាំកិច្ចប្រជុំ គ.ហ.ស. ដើម្បីពិនិត្យ និងពិភាក្សាលើរបាយការណ៍តាមដាន និងវាយតម្លៃប្រចាំឆ្នាំ ២០២៥ នៃការអនុវត្តកម្មវិធីកែទម្រង់ការគ្រប់គ្រងហិរញ្ញវត្ថុសាធារណៈ ដំណាក់កាលទី៤ «គណនេយ្យភាពសមិទ្ធកម្ម»។ កិច្ចប្រជុំនេះ មានការអញ្ជើញចូលរួមពីសំណាក់ **ឯកឧត្តម លោកជំទាវ លោក លោកស្រី** ដែលជាថ្នាក់ដឹកនាំ និងមន្ត្រីពីគ្រប់អង្គភាពក្រោមឱវាទ **កសហវ.** រួមទាំង មន្ទីរ **សហវ.** រាជធានី-ខេត្ត ក្រសួង-ស្ថាប័ន និងរដ្ឋបាលរាជធានី-ខេត្តទាំង ២៥។

ផ្អែកតាមរបាយការណ៍តាមដាន និងវាយតម្លៃប្រចាំឆ្នាំ២០២៥ **«ភាពជឿទុកចិត្តនៃថវិកា»** រក្សាបាននូវភាពធន់នៃប្រព័ន្ធ ដែលឆ្លុះបញ្ចាំងតាមរយៈការកើនឡើងចំណូលធៀបនឹងឆ្នាំ២០២៤ និងស្ថិតក្នុងរង្វង់ +/- ៥% ធៀបនឹងច្បាប់។ បន្ថែមពីនេះ ការគ្រប់គ្រង និងកៀរគរចំណូលថវិកាជាតិ ត្រូវបានរំពឹងទុកថានឹងមានភាពល្អប្រសើរឡើងថែមមួយកម្រិតទៀត តាមរយៈការអនុវត្តយ៉ាងម៉ឺងម៉ាត់នូវយុទ្ធសាស្ត្រ និង ឯកសារគោលពាក់ព័ន្ធទាំងចំណូលសារពើពន្ធ និងចំណូលមិនមែនសារពើពន្ធ។ រីឯចំណាយថវិកាជាតិ ក៏ត្រូវបានបន្តលើកកម្ពស់ប្រសិទ្ធភាព តាមរយៈការអនុវត្តយ៉ាងម៉ត់ចត់នូវវិធានការនានា ជាពិសេសវិធានការទាំងឡាយដែលបានកំណត់នៅក្នុងផែនទីបង្ហាញផ្លូវសម្រាប់គ្រប់គ្រងចំណាយកកស្ទះ។

ទន្ទឹមនឹងនេះ របាយការណ៍ក៏បានគូសរំលេចផងដែរថា «**គណនេយ្យភាពហិរញ្ញវត្ថុ**» ត្រូវបានបន្តកសាងតាមរយៈការដាក់ឱ្យអនុវត្តស្តង់ដាគណនេយ្យសាធារណៈ ជាជំហានៗ, ការពង្រឹងនិងពង្រីកការអនុវត្ត

ប្រព័ន្ធបច្ចេកវិទ្យាព័ត៌មានសម្រាប់ការគ្រប់គ្រងហិរញ្ញវត្ថុសាធារណៈ (FMIS), ការពង្រឹងការគ្រប់គ្រងទ្រព្យសម្បត្តិរដ្ឋ, ការគ្រប់គ្រងបំណុលសាធារណៈ, ព្រមទាំងការគ្រប់គ្រងសហគ្រាសសាធារណៈ និងគ្រឹះស្ថានសាធារណៈរដ្ឋបាល ជាដើម។ ដោយឡែក «**ការផ្សារភ្ជាប់ថវិកាទៅនឹងគោលនយោបាយ**» ក៏មានឧបករណ៍គ្រប់គ្រាន់ស្របទៅតាមឧត្តមានុវត្តអន្តរជាតិ និងបានចាក់ឫសគល់នៅគ្រប់ក្រសួង ស្ថាប័ន នៃរាជរដ្ឋាភិបាលទាំងអស់ ខណៈ «**គណនេយ្យភាពចំពោះសមិទ្ធកម្ម**» ត្រូវបានបន្តកសាងបន្ថែម តាមរយៈការដាក់ចេញនូវវិធានការ និងលិខិតបទដ្ឋានគតិយុត្តពាក់ព័ន្ធ ទាំងការដាក់ឱ្យអនុវត្តក្របខ័ណ្ឌថវិកាព័ត៌មានសមិទ្ធកម្ម, ការអនុវត្តក្របខ័ណ្ឌតាមដាន និងវាយតម្លៃសមិទ្ធកម្ម, ប្រព័ន្ធត្រួតពិនិត្យ, និងតម្លាភាពថវិកា។

ជារួម «**ប្រព័ន្ធហិរញ្ញវត្ថុសាធារណៈកម្ពុជា**» នៅតែរក្សាបាននូវភាពធន់ និងបន្តរួមចំណែកដ៏សំខាន់ជាមួយរាជរដ្ឋាភិបាល ក្នុងការទ្រទ្រង់ស្ថិរភាព និងកំណើនសេដ្ឋកិច្ច ជាពិសេស ក្នុងបរិការណ៍ នៃវិបត្តិកើតឡើងផ្ទួនៗ ទាំងក្នុងតំបន់ និងសកលលោក។ បន្ថែមពីនេះ «**វប្បធម៌សមិទ្ធកម្ម**» ក៏ត្រូវបានបណ្តុះឱ្យចាក់ឫសគល់កាន់តែជ្រៅនៅគ្រប់ក្រសួង ស្ថាប័ន ដើម្បីធានាបាននូវការអភិវឌ្ឍសេដ្ឋកិច្ចនិងសង្គមជាតិយូរអង្វែងស្របតាមចក្ខុវិស័យរបស់កម្ពុជា។

ឆ្លៀតក្នុងឱកាសនេះ **ឯកឧត្តមអគ្គបណ្ឌិតសភាចារ្យ ឧបនាយករដ្ឋមន្ត្រី** បានរំលឹកផងដែរថា ក្នុងស្មារតី នៃឆន្ទៈមោះមុតដើម្បីការអភិវឌ្ឍសង្គមសេដ្ឋកិច្ចប្រកបដោយចីរភាព, អង្គភាព/ស្ថាប័នទាំងនៅថ្នាក់ជាតិ និងថ្នាក់ក្រោមជាតិ ដែលចូលរួមអនុវត្តកម្មវិធីកែទម្រង់ការគ្រប់គ្រងហិរញ្ញវត្ថុសាធារណៈចាំបាច់ត្រូវបន្តពង្រឹងនូវគុណភាព នៃធាតុគន្លឹះៗទាំងឡាយ ឬ អនុវត្តដោយមិនបន្ធូរ ឬ បង្អង់ដៃ នូវវិធានការដែលកំណត់នៅក្នុងផែនការសកម្មភាពរួម, សេចក្តីសម្រេចប្រតិបត្តិរបស់ **គ.ហ.ស.** ឬ ឯកសារគោល និងយុទ្ធសាស្ត្រនានា សំដៅធានាឱ្យបាននូវប្រព័ន្ធហិរញ្ញវត្ថុសាធារណៈទំនើប សំដៅឈានទៅអនុវត្តជាមូលដ្ឋាននូវ «**ប្រព័ន្ធថវិកាព័ត៌មានសមិទ្ធកម្ម**» ក្នុងឆ្នាំ២០២៦។

មុននឹងបញ្ចប់, **ឯកឧត្តមអគ្គបណ្ឌិតសភាចារ្យ ឧបនាយករដ្ឋមន្ត្រី** បានវាយតម្លៃខ្ពស់ចំពោះថ្នាក់ដឹកនាំ និងសហការី នៃអគ្គលេខាធិការដ្ឋានគណៈកម្មាធិការដឹកនាំការងារកែទម្រង់ការគ្រប់គ្រងហិរញ្ញវត្ថុសាធារណៈ ដែលបានរៀបចំរបាយការណ៍ ដែលមានលក្ខណៈគ្រប់ជ្រុងជ្រោយ និងប្រកបដោយវិជ្ជាជីវៈ។ ទន្ទឹមនឹងនេះ **ឯកឧត្តមអគ្គបណ្ឌិតសភាចារ្យ ឧបនាយករដ្ឋមន្ត្រី** ក៏បានកោតសរសើរចំពោះថ្នាក់ដឹកនាំ និងមន្ត្រី នៃគ្រប់អង្គភាពក្រោមឱវាទ **កសហវ.** រួមទាំង មន្ទីរ **សហវ.** រាជធានី-ខេត្ត ក្រសួង-ស្ថាប័ន និងរដ្ឋបាលរាជធានី-ខេត្តទាំង ២៥ គ្រប់លំដាប់ថ្នាក់ ដែលបានចូលរួមអនុវត្តការងារកែ-ទម្រង់ការគ្រប់គ្រងហិរញ្ញវត្ថុសាធារណៈ ប្រកបដោយឆន្ទៈមោះមុត និងភាពជាម្ចាស់ខ្ពស់ ចាប់ពីដើម រហូតដល់ដំណាក់កាលទី៤ ដែលជាដំណាក់ចុងក្រោយនេះ។